# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៨៣៩,៣៦៣ ដុល្លាអាមេរិកដើម្បីបង្កើនប្រសិទ្ធភាពបោសសម្អាតមីន ក្នុងខេត្តបាត់ដំបង



ក្រោមគ្រោងការណ៍នៃជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ¥៦៧,៩៨៨,៤០៣ស្មើនឹង ៨៣៩,៣៦៣ដុល្លាអាមេរិកដល់អង្គការសកម្មភាពកំចាត់មីនជប៉ុន(JMAS)។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានាថ្ងៃនេះនៅស្ថានទូតជប៉ុនដោយឯកឧត្តមម៉ាសាហ៊្វូមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក យ៉ាស៊ូយូគិ តានីហ្គាវ៉ា ប្រធានតំណាងអង្គការJMASដើម្បីអនុវត្តគម្រោងបង្កើនប្រសិទ្ធភាពបោសសម្អាតមីននៅខេត្តបាត់ដំបង។



គម្រោងនេះគឺដើម្បីពង្រាយម៉ាស៊ីនកំទេចមីនមួយគ្រឿង និងម៉ាស៊ីនកាត់ស្មៅមួយគ្រឿង និងក្រុមប្រតិបត្តិការបោសសម្អាតមីន២ក្រុម ព្រមទាំងផ្តល់ជំនួយបច្ចេកទេសពីទីប្រឹក្សារបស់JMASនៅភូមិជាមន្ត្រី ភូមិស្វាយស ភូមិប្រជៀវ និងភូមិជីសាង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង។ យើងរំពឹងថា គម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ៥,៥០០នាក់ដោយកាត់បន្ថយការគំរាមកំហែងពីគ្រាប់មីន និងឈានទៅអភិវឌ្ឍន៍សហគមន៍នៅពេលដែលតំបន់នោះត្រូវបានរំដោះមីនរួច។ ជាងនេះទៅទៀត ជាផ្នែកមួយនៃការផ្ទេរបច្ចេកទេស JMASគ្រោងនឹងប្រើប្រាស់ "សៀវភៅណែនាំអំពីប្រតិបត្តិការ" ដែលរៀបរៀងដោយ JMAS និង CMAC ក្នុងគម្រោងមុនដែលថ្នាក់ដឹកនាំរបស់CMACអាចប្រើប្រាស់នៅទីលានបោសសម្អាតមីនប្រកបដោយសុវត្ថិភាព និងកាន់តែមានប្រសិទ្ធភាព។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ដើម្បីគាំទ្រសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង១៥.៥លានដុល្លាអាមេរិក ដល់គម្រោងចំនួន៦៦គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល និង សកម្មភាពបោសសំអាតមីន។ គម្រោងរបស់អង្គការJMASនេះគឺជាគម្រោងទី២តាម រយៈគ្រោងការណ៍នៃជំនួយនេះសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១២របស់ជប៉ុន(មេសា២០១២ដល់មិនា២០១៣)។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*